នស/រកត/១០១៥/១១៧៥

# ព្រះរាជក្រឹត្យ

## ស្តីពី

## គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា ១**:

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់គោលការណ៍រួមថ្មីនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ព្រមទាំងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដែលកំណត់ដោយលក្ខន្តិកៈដោយឡែក។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ក្រសួងព្រះបរមរាជវាំង

**មាត្រា ២**:

ព្រះរាជក្រឹត្យនេះ មានគោលដៅដើម្បីរៀបចំមន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្រោមអង្គ កំណត់មុខតំណែង ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ និងសន្ទស្សន៍បៀវត្ស ព្រមទាំងរៀបចំសមាហរណកម្មមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ និងសន្ទស្សន៍បៀវត្សថ្មី។

**មាត្រា ៣**:

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងបំពេញការងារនៅក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

## ជំពូកទី ២
## អំពីអង្គ

**មាត្រា ៤**:

អង្គនៃមន្ត្រីរាជការស៊ីវិល សំដៅដល់ការប្រមូលផ្តុំមន្ត្រីរាជការស៊ីវិលដែលទទួលការបណ្តុះបណ្តាលមានបទពិសោធន៍ការងារ និងចំណេះដឹង ព្រមទាំងបំពេញការងារក្នុងវិស័យតែមួយ។

អង្គនីមួយៗ អាចមានប្រភេទក្របខណ្ឌចំនួន ៣(បី) គឺក្របខណ្ឌប្រភេទ ក ក្របខណ្ឌប្រភេទ ខ និងក្របខណ្ឌប្រភេទ គ។

**មាត្រា ៥**:

អង្គនីមួយៗ ត្រូវរៀបចំឱ្យមានការកំណត់និងបែងចែកប្រភេទមុខតំណែងច្បាស់លាស់ ការពិពណ៌នាមុខតំណែង និងគុណវុឌ្ឍិសម្រាប់មុខតំណែងនីមួយៗ ដោយផ្សារភ្ជាប់ទៅនឹងប្រភេទក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់។

**មាត្រា ៦**:

អង្គនីមួយៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ និង ត្រូវរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធរួមសហការជាមួយក្រសួងមុខងារសាធារណៈ។ ការរៀបចំអាជីពមន្ត្រីរាជការស៊ីវិលក្នុងអង្គ ត្រូវកំណត់អនុលោមបទបញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជានិងព្រះរាជក្រឹត្យនេះ។

ការរៀបចំមុខតំណែងនិងក្របខណ្ឌក្នុងអង្គ ត្រូវអនុវត្តអនុលោមបទញ្ញត្តិនៃជំពូកទី៣ និង ជំពូកទី៤ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី ៣
## ការរៀបចំមុខតំណែង

**មាត្រា ៧**:

គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវរៀបចំនិងកំណត់ឱ្យបានច្បាស់លាស់អំពីមុខតំណែងទាំងអស់ទៅតាមអង្គនីមួយៗ ព្រមទាំងចំនួនសម្រាប់មុខតំណែងដែលជាតម្រូវការការងារក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រតិបត្តិការការងារ និងបំពេញបេសកកម្មនិងមុខងាររបស់ក្រសួង ស្ថាប័ន។

ការកំណត់និងបែងចែកប្រភេទមុខតំណែងក្នុងអង្គ ដើម្បីគាំទ្រដំណើរការការងារនិងបេសកកម្មរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ដោយមានការផ្តល់យោបល់ពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៨:**

មុខតំណែងបំពេញដោយមន្ត្រីរាជការស៊ីវិលក្នុងមុខងារសាធារណៈ ត្រូវជាមុខតំណែងដែលមានលក្ខណៈអចិន្ត្រៃយ៍ដែលតម្រូវឱ្យបំពេញការងារពេញម៉ោង ស្របតាមចំនួនម៉ោង និងពេលវេលាកំណត់ដោយរាជរដ្ឋាភិបាល។ មុខតំណែងនីមួយៗ ត្រូវមានបញ្ជាក់យ៉ាងហោចនូវព័ត៌មានដូចខាងក្រោម៖

១. ប្រភេទអង្គ ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់

២. ឈ្មោះនៃមុខតំណែងក្នុងអង្គ

៣. គុណវុឌ្ឍិសម្រាប់មុខតំណែង

៤. ការពិពណ៌នាមុខតំណែងដែលរួមមានការបញ្ជាក់អំពីមុខងារ អង្គភាព និងទីកន្លែងការងារ។

មន្ត្រីរាជការស៊ីវិល មិនត្រូវបានអនុញ្ញាតឱ្យកាន់មុខតំណែងដែលមានលក្ខណៈអចិន្ត្រៃយ៍លើសពីមួយមុខតំណែងឡើយ ទោះក្នុងក្រសួង ស្ថាប័នតែមួយ ឬ ក្នុងក្រសួង ស្ថាប័នផ្សេងគ្នា។

## ជំពូកទី ៤

## ក្របខណ្ឌ

**មាត្រា ៩:**

ក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៃអង្គនីមួយៗ គឺជាការប្រមូលផ្តុំមន្ត្រីរាជការស៊ីវិលដែលមានគុណសម្បត្តិ ឬ ការបណ្តុះបណ្តាលដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ហើយដែលមានឧបនិស្ស័យកាន់មុខតំណែង ឬ បំពេញមុខងារដូចគ្នាក្នុងអង្គតែមួយ។

**មាត្រា ១០:**

ក្របខណ្ឌមន្ត្រីរាជការស៊ីវិលទាំង៣(បី)ប្រភេទនៃអង្គនីមួយៗ ត្រូវបានរៀបចំឡើងផ្អែកលើលក្ខខណ្ឌអប្បបរមានៃការបណ្តុះបណ្តាលក្នុងអង្គនោះ សម្រាប់បញ្ចូលក្នុងក្របខណ្ឌនិងកម្រិតឋានានុក្រមនៃក្របខណ្ឌ។

ការកំណត់លំដាប់ឋានន្តរស័ក្តិនិងការបែងចែកជាថ្នាក់ក្នុងក្របខណ្ឌនីមួយៗ ត្រូវអនុវត្តអនុលោមបទបញ្ញត្តិនៃជំពូកទី៥នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ១១:**

មន្ត្រីរាជការស៊ីវិលក្របខណ្ឌប្រភេទ ក អាចមានមុខងារក្នុងតំណែងដឹកនាំ គ្រប់គ្រង អធិការកិច្ចសវនកម្ម បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់យោបល់ គោលនយោបាយ ផែនការ និងទទួលខុសត្រូវអាស្រ័យតាមអង្គ។

កម្រិតអប្បបរមានៃការបណ្តុះបណ្តាល ដើម្បីអាចបញ្ចូលក្នុងក្របខណ្ឌប្រភេទ ក គឺសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល។ លក្ខន្តិកៈដោយឡែកក្នុងអង្គ អាចកំណត់កម្រិតអប្បបរមានៃការបណ្តុះបណ្តាលលើសពីកម្រិតបរិញ្ញាបត្រ ក្នុងករណីនេះ មន្ត្រីរាជការស៊ីវិល ត្រូវទទួលបានការផ្តល់មួយថ្នាក់បន្ថែមនៅពេលតាំងស៊ប់។

**មាត្រា ១២:**

មន្ត្រីរាជការស៊ីវិលក្របខណ្ឌប្រភេទ ខ អាចមានមុខងារក្នុងការរៀបចំការងារសម្រាប់អ្នកទទួលខុសត្រូវសម្រេចនិងដាក់ឱ្យអនុវត្ត ការងារបណ្តុះបណ្តាល ជានាប្រតិបត្តិការនៃការងារ និងជួយគាំទ្រដល់ការងារមន្ត្រីរាជការស៊ីវិលក្របខណ្ឌប្រភេទ ក អាស្រ័យតាមអង្គ។

កម្រិតអប្បបរមា ដើម្បីអាចបញ្ចូលក្នុងក្របខណ្ឌប្រភេទ ខ គឺសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក២(ពីរ)ឆ្នាំនៃការសិក្សាដោយមានសញ្ញាបត្រ។ លក្ខន្តិកៈដោយឡែកក្នុងអង្គ អាចកំណត់កម្រិតអប្បបរមានៃការបណ្តុះបណ្តាលលើសពី២(ពីរ)ឆ្នាំនៃការសិក្សាដោយមានសញ្ញាបត្រ ប៉ុន្តែមិនត្រូវស្មើនឹងចំនួនឆ្នាំនៃការសិក្សាកំណត់ដោយក្របខណ្ឌប្រភេទ ក ក្នុងអង្គតែមួយឡើយ។ ក្នុងករណីនេះ មន្ត្រីរាជការស៊ីវិល ត្រូវទទួលបានការផ្តល់មួយថ្នាក់បន្ថែមនៅពេលតាំងស៊ប់។

**មាត្រា ១៣:**

មន្ត្រីរាជការស៊ីវិលក្របខណ្ឌប្រភេទ គ អាចមានមុខងារក្នុងការរៀបចំការងារការិយាល័យ លេខាធិការដ្ឋាន ការងារបណ្តុះបណ្តាលកម្រិតបឋម និងប្រតិបត្តិការធម្មតា ដែលតម្រូវឱ្យមានចំណេះបច្ចេកទេស ឬ ចំណេះធ្វើការងារជាក់លាក់ដែលជាការតម្រូវនៃអង្គ។

លក្ខន្តិកៈដោយឡែកក្នុងអង្គ អាចកំណត់កម្រិតអប្បបរមានៃការបណ្តុះបណ្តាលចំណេះដឹងទូទៅ ឬ បច្ចេកទេស ដោយមានសញ្ញាបត្រ ឬ វិញ្ញាបនបត្របញ្ជាក់ ប៉ុន្តែការកំណត់នេះ មិនត្រូវដូចគ្នានឹងលក្ខខណ្ឌកំណត់ដោយក្របខណ្ឌប្រភេទ ខ ក្នុងអង្គតែមួយឡើយ។

**មាត្រា ១៤:**

ក្របខណ្ឌក្នុងអង្គនីមួយៗ ត្រូវមានជាចាំបាច់នូវការកំណត់ដូចខាងក្រោម៖

ក. ការភ្ជាប់ក្របខណ្ឌទៅនឹងអង្គណាមួយ

ខ. ការចាត់លំដាប់ថ្នាក់ក្របខណ្ឌទៅក្នុងប្រភេទណាមួយ

គ. បេសកកម្មទូទៅរបស់ក្របខណ្ឌ

ឃ. មុខតំណែង ការពិព័ណ៌នាមុខតំណែង និងគុណវុឌ្ឍិពាក់ព័ន្ធ

ង. លក្ខណសម្បត្តិអប្បបរមា ដើម្បីបញ្ចូលក្នុងក្របខណ្ឌនិងបែបបទនៃការប្រឡងប្រជែងផ្ទៃក្នុងនិងការប្រឡងប្រជែងចូលក្របខណ្ឌមន្ត្រីរាជការស៊ីវិល

ច. របបកម្មសិក្សា

ឆ. ឋានានុក្រមក្នុងក្របខណ្ឌរួមមាន ការបែងចែកក្របខណ្ឌជាឋានន្តរស័ក្តិ ឬ ថ្នាក់និងការកំណត់មុខតំណែង

ជ. វិធានសម្រាប់ការកាន់មុខតំណែង ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ។

## ជំពូកទី ៥

## ឋានន្តរស័ក្តិ ថ្នាក់ និងសន្ទស្សន៍បៀវត្សមូលដ្ឋាន

**មាត្រា ១៥:**

ឋានន្តរស័ក្តិ គឺជាលំដាប់ឋានានុក្រមនៃក្របខណ្ឌក្នុងអង្គនីមួយៗ។ ក្របខណ្ឌ ក និង ក្របខណ្ឌ ខ ត្រូវបានរៀបចំបែងចែកជា ៣(បី) ឋានន្តរស័ក្តិ។ ឋានន្តរស័ក្តិនីមួយៗ ឆ្លើយតបទៅនឹងមុខតំណែង ឬ សាព័ន្ធមុខងារដែលមានការទទួលខុសត្រូវកាន់តែខ្ពស់។

**មាត្រា ១៦:**

ក្របខណ្ឌ គ ពុំត្រូវបានរៀបចំបែងចែកជាឋានន្តរស័ក្តិនោះទេ។

ក្របខណ្ឌ គ មានចំនួនថ្នាក់សរុប ១០(ដប់)ថ្នាក់ ដោយរាប់ពីថ្នាក់លេខ ១០(ដប់)ឡើងទៅថ្នាក់ខ្ពស់បំផុតលេខ ១(មួយ)។

**មាត្រា ១៧:**

ក្របខណ្ឌ ក និង ក្របខណ្ឌ ខ មានចំនួនថ្នាក់សរុប ១៤(ដប់បួន) ក្នុងក្របខណ្ឌនីមួយៗ ដោយត្រូវបានរៀបចំជាឋានន្តរស័ក្តិនិងថ្នាក់ដូចខាងក្រោម៖

- ឋានន្តរស័ក្តិទី៣(បី) គឺជាឋានន្តរស័ក្តិទាបបំផុត ដែលមាន ៤(បួន)ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ៤(បួន) ដល់ លេខ១(មួយ)
- ឋានន្តរស័ក្តិទី២(ពីរ) គឺជាឋានន្តរស័ក្តិខ្ពស់បន្ទាប់ ដែលមាន ៤(បួន)ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ៤(បួន) ដល់ លេខ១(មួយ)
- ឋានន្តរស័ក្តិទី១(មួយ) គឺជាឋានន្តរស័ក្តិខ្ពស់បំផុត ដែលមាន ៦(ប្រាំមួយ)ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ៦(ប្រាំមួយ) ដល់ លេខ១(មួយ)។

**មាត្រា ១៨**:

ថ្នាក់ក្នុងឋានន្តរស័ក្តិនៃក្របខណ្ឌ ក និង ក្របខណ្ឌ ខ និង ថ្នាក់នៃក្របខណ្ឌ គ ត្រូវបានកំណត់ឱ្យមានសន្ទស្សន៍បញ្ជាក់អំពីកម្រិតលាភការដែលជាបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល។

កម្រិតសន្ទស្សន៍ថ្មី ត្រូវបានកំណត់ក្នុងតារាងដូចខាងក្រោម៖

| **ប្រភេទក្របខណ្ឌ** | **ឋានន្តរស័ក្តិ** | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ក** | ៣ | | | | ២ | | | | ១ | | | | | |
| | **ថ្នាក់** | | | | **ថ្នាក់** | | | | **ថ្នាក់** | | | | | |
| | ៤ | ៣ | ២ | ១ | ៤ | ៣ | ២ | ១ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | **សន្ទស្សន៍បៀវត្ស** | | | | **សន្ទស្សន៍បៀវត្ស** | | | | **សន្ទស្សន៍បៀវត្ស** | | | | | |
| | ៣៤៥ | ៣៥៤ | ៣៦៤ | ៣៧៩ | ៣៩៤ | ៤១០ | ៤២៦ | ៤៤៣ | ៤៦១ | ៤៧៩ | ៤៩៦ | ៥១៣ | ៥៣១ | ៥៥០ |
| **ប្រភេទក្របខណ្ឌ** | **ឋានន្តរស័ក្តិ** | | | | | | | | | | | | | |
| **ខ** | ៣ | | | | ២ | | | | ១ | | | | | |
| | **ថ្នាក់** | | | | **ថ្នាក់** | | | | **ថ្នាក់** | | | | | |
| | ៤ | ៣ | ២ | ១ | ៤ | ៣ | ២ | ១ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | **សន្ទស្សន៍បៀវត្ស** | | | | **សន្ទស្សន៍បៀវត្ស** | | | | **សន្ទស្សន៍បៀវត្ស** | | | | | |
| | ៣០០ | ៣០៨ | ៣១៨ | ៣៣១ | ៣៤៤ | ៣៥៨ | ៣៦៩ | ៣៨០ | ៣៩៣ | ៤០៧ | ៤២១ | ៤៣៦ | ៤៥៣ | ៤៧០ |
| **ប្រភេទក្របខណ្ឌ** | | | | | **ថ្នាក់** | | | | | | | | | |
| **គ** | | | | | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | | | | | **សន្ទស្សន៍បៀវត្ស** | | | | | | | | | |
| | | | | | ២៦៥ | ២៧៤ | ២៨៤ | ២៩៥ | ៣០៧ | ៣២១ | ៣៣៥ | ៣៥២ | ៣៧០ | ៣៩០ |

## ជំពូកទី ៦

## សមាហរណកម្មក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់

**មាត្រា ១៩**:

មន្ត្រីរាជការស៊ីវិលនៃប្រភេទក្របខណ្ឌ ក ខ គ និង ឃ បច្ចុប្បន្ន នឹងត្រូវធ្វើសមាហរណកម្មផ្អែកលើប្រភេទក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់។

ការធ្វើសមាហរណកម្មខាងលើ នឹងរៀបចំមន្ត្រីរាជការស៊ីវិលបច្ចុប្បន្នទៅក្នុងប្រភេទក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដែលមានកម្រិត ឬ សន្ទស្សន៍បៀវត្សខ្ពស់ជាង ឬ យ៉ាងហោចស្មើនឹងកម្រិត ឬ សន្ទស្សន៍បៀវត្សនៃថ្នាក់បច្ចុប្បន្នរបស់ខ្លួន។

**មាត្រា ២០:**

មន្ត្រីរាជការស៊ីវិលនៃប្រភេទក្របខណ្ឌ ក បច្ចុប្បន្ន នឹងត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មីដូចបានកំណត់ក្នុងតារាងខាងក្រោម៖

| ក្របខណ្ឌ ឋានន្តរស័ក្តិនិងថ្នាក់បច្ចុប្បន្ន | កម្រិតសន្ទស្សន៍បៀវត្សបច្ចុប្បន្នដែលកែសម្រួលបន្ទាប់ពីបន្ថែម ៤០.០០០រៀលក្នុង១ខែ | ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់បច្ចុប្បន្នដែលត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិនិងថ្នាក់ថ្មី | ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី | សន្ទស្សន៍បៀវត្សថ្មី | ប្រាក់បង្គ្រប់ប្រចាំខែបន្ថែម |
|---|---|---|---|---|---|
| ក.១.១ | ៥៧៦ | ក.១.១ | ក.១.១ | ៥៥០ | ៤០.០០០៛ |
| ក.១.២ | ៥៥៤ | ក.១.២ | | | ៧.០០០៛ |
| ក.១.៣ | ៥៣២ | ក.១.៣ | | | |
| ក.១.៤ | ៥០៨ | ក.២.១ | ក.១.២ | ៥៣១ | |
| ក.១.៥ | ៤៨៣ | ក.១.៤ | ក.១.៣ | ៥១៣ | |
| ក.១.៦ | ៤៦២ | ក.២.២ | | | |
| ក.២.១ | ៥១៣ | ក.១.៥ | ក.១.៤ | ៤៩៦ | |
| ក.២.២ | ៥០៤ | ក.២.៣ | | | |
| ក.២.៣ | ៤៩៣ | ក.២.៤ | | | |
| ក.២.៤ | ៤៨០ | ក.១.៦ | ក.១.៥ | ៤៧៩ | |
| ក.២.៥ | ៤៦៣ | ក.២.៥ | | | |
| ក.២.៦ | ៤៤៥ | ក.២.៦ | ក.១.៦ | ៤៦១ | |
| ក.២.៧ | ៤២៨ | ក.៣.១ | | | |
| ក.២.៨ | ៤១៣ | ក.៣.២ | | | |
| ក.២.៩ | ៣៩៩ | ក.២.៧ | ក.២.១ | ៤៤៣ | |
| ក.២.១០ | ៣៨៧ | ក.៣.៣ | | | |
| ក.៣.១ | ៤៥១ | ក.៣.៤ | | | |
| ក.៣.២ | ៤៤៦ | ក.២.៨ | ក.២.២ | ៤២៦ | |
| ក.៣.៣ | ៤៤០ | ក.៣.៥ | | | |
| ក.៣.៤ | ៤៣៣ | ក.៣.៦ | | | |
| ក.៣.៥ | ៤២៥ | ក.២.៩ | ក.២.៣ | ៤១០ | |
| ក.៣.៦ | ៤១៦ | ក.៣.៧ | | | |
| ក.៣.៧ | ៤០៧ | ក.៣.៨ | | | |
| ក.៣.៨ | ៣៩៥ | ក.២.១០ | ក.២.៤ | ៣៩៤ | |
| ក.៣.៩ | ៣៨៥ | ក.៣:៩ | | | |
| ក.៣.១០ | ៣៧៥ | ក.៣.១០ | ក.៣.១ | ៣៧៩ | |
| ក.៣.១១ | ៣៦៦ | ក.៣.១១ | | | |
| ក.៣.១២ | ៣៥៧ | ក.៣.១២ | ក.៣.២ | ៣៦៤ | |
| ក.៣.១៣ | ៣៤៩ | ក.៣.១៣ | ក.៣.៣ | ៣៥៤ | |
| ក.៣.១៤ | ៣៤១ | ក.៣.១៤ | ក.៣.៤ | ៣៤៥ | |

ប្រាក់បង្គ្រប់ប្រចាំខែបន្ថែមដែលមានកំណត់នៅក្នុងតារាងខាងលើ ត្រូវអនុវត្តសម្រាប់មន្ត្រីរាជការស៊ីវិលថ្នាក់ ក.១.១ និង ក.១.២ នៃក្របខណ្ឌបច្ចុប្បន្នដែលត្រូវធ្វើសមាហរណកម្មទៅក្នុងថ្នាក់ ក.១.១ នៃប្រភេទក្របខណ្ឌ ក ថ្មី តែប៉ុណ្ណោះ។

**មាត្រា ២១:**

មន្ត្រីរាជការស៊ីវិលនៃប្រភេទក្របខណ្ឌ ខ បច្ចុប្បន្ន នឹងត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មីដូចបានកំណត់ក្នុងតារាងខាងក្រោម៖

| ក្របខណ្ឌ ឋានន្តរស័ក្តិនិង ថ្នាក់បច្ចុប្បន្ន | សន្ទស្សន៍បៀវត្សបច្ចុប្បន្ន ដែលកែសម្រួលបន្ទាប់ពីបន្ថែម ៨០.០០០រៀលក្នុង១ខែ |
|---|---|
| ខ.១.១ | ៤៣៨ |
| ខ.១.២ | ៤២៧ |
| ខ.១.៣ | ៤១៣ |
| ខ.១.៤ | ៣៩៧ |
| ខ.១.៥ | ៣៧៧ |
| ខ.១.៦ | ៣៦១ |
| ខ.២.១ | ៣៩៣ |
| ខ.២.២ | ៣៨៦ |
| ខ.២.៣ | ៣៧៨ |
| ខ.២.៤ | ៣៦៩ |
| ខ.២.៥ | ៣៥៩ |
| ខ.២.៦ | ៣៤៨ |
| ខ.២.៧ | ៣៣៦ |
| ខ.២.៨ | ៣២៥ |
| ខ.២.៩ | ៣១៥ |
| ខ.២.១០ | ៣០៥ |
| ខ.៣.១ | ៣៥០ |
| ខ.៣.២ | ៣៤៦ |
| ខ.៣.៣ | ៣៤២ |
| ខ.៣.៤ | ៣៣៧ |
| ខ.៣.៥ | ៣៣២ |
| ខ.៣.៦ | ៣២៦ |
| ខ.៣.៧ | ៣១៩ |
| ខ.៣.៨ | ៣១២ |
| ខ.៣.៩ | ៣០៤ |
| ខ.៣.១០ | ២៩៦ |
| ខ.៣.១១ | ២៨៩ |
| ខ.៣.១២ | ២៨៣ |
| ខ.៣.១៣ | ២៧៨ |
| ខ.៣.១៤ | ២៧៣ |

| ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់បច្ចុប្បន្ន ដែលត្រូវធ្វើសមាហរណកម្មទៅក្នុង ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី | ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី | សន្ទស្សន៍ បៀវត្សថ្មី |
|---|---|---|
| ខ.១.១ | ខ.១.១ | ៤៧០ |
| ខ.១.២ | ខ.១.២ | ៤៥៣ |
| ខ.១.៣ | ខ.១.៣ | ៤៣៦ |
| ខ.១.៤ | ខ.១.៤ | ៤២១ |
| ខ.១.៥ | ខ.១.៥ | ៤០៧ |
| ខ.២.១ | | |
| ខ.១.៦ | ខ.១.៦ | ៣៩៣ |
| ខ.២.២ | | |
| ខ.២.៣ | ខ.២.១ | ៣៨០ |
| ខ.២.៤ | | |
| ខ.២.៥ | ខ.២.២ | ៣៦៩ |
| ខ.២.៦ | ខ.២.៣ | ៣៥៨ |
| ខ.៣.១ | | |
| ខ.៣.២ | | |
| ខ.២.៧ | ខ.២.៤ | ៣៤៤ |
| ខ.២.៨ | | |
| ខ.២.៩ | | |
| ខ.២.១០ | | |
| ខ.៣.៣ | | |
| ខ.៣.៤ | | |
| ខ.៣.៥ | | |
| ខ.៣.៦ | ខ.៣.១ | ៣៣១ |
| ខ.៣.៧ | | |
| ខ.៣.៨ | ខ.៣.២ | ៣១៨ |
| ខ.៣.៩ | ខ.៣.៣ | ៣០៨ |
| ខ.៣.១០ | ខ.៣.៤ | ៣០០ |
| ខ.៣.១១ | | |
| ខ.៣.១២ | | |
| ខ.៣.១៣ | | |
| ខ.៣.១៤ | | |

**មាត្រា ២២:**

មន្ត្រីរាជការស៊ីវិលនៃប្រភេទក្របខណ្ឌ គ បច្ចុប្បន្ន នឹងត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មីដូចបានកំណត់ក្នុងតារាងខាងក្រោម៖

| ក្របខណ្ឌ ឋានន្តរស័ក្តិនិង ថ្នាក់បច្ចុប្បន្ន | សន្ទស្សន៍បៀវត្សបច្ចុប្បន្ន ដែលកែសម្រួលបន្ទាប់ពីបន្ថែម ៨០.០០០រៀលក្នុង១ខែ |
|---|---|
| គ.១.១ | ៣១៥ |
| គ.១.២ | ៣០៧ |
| គ.១.៣ | ២៩៨ |
| គ.១.៤ | ២៨៨ |
| គ.១.៥ | ២៧៦ |
| គ.១.៦ | ២៦៥ |
| គ.២.១ | ២៨៦ |
| គ.២.២ | ២៨១ |
| គ.២.៣ | ២៧៥ |
| គ.២.៤ | ២៦៨ |
| គ.២.៥ | ២៦៣ |
| គ.២.៦ | ២៦៣ |
| គ.២.៧ | ២៦៣ |
| គ.២.៨ | ២៦៣ |
| គ.២.៩ | ២៦៣ |
| គ.២.១០ | ២៦៣ |
| គ.៣.១ | ២៦៣ |
| គ.៣.២ | ២៦៣ |
| គ.៣.៣ | ២៦៣ |
| គ.៣.៤ | ២៦៣ |
| គ.៣.៥ | ២៦៣ |
| គ.៣.៦ | ២៦៣ |
| គ.៣.៧ | ២៦៣ |
| គ.៣.៨ | ២៦៣ |
| គ.៣.៩ | ២៦៣ |
| គ.៣.១០ | ២៦៣ |
| គ.៣.១១ | ២៦៣ |
| គ.៣.១២ | ២៦៣ |
| គ.៣.១៣ | ២៦៣ |
| គ.៣.១៤ | ២៦៣ |
| | |
| | |
| | |
| | |
| | |

| ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់បច្ចុប្បន្ន ដែលត្រូវធ្វើសមាហរណកម្មទៅក្នុង ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី | ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី | សន្ទស្សន៍ បៀវត្សថ្មី |
|---|---|---|
| | | |
| | គ.១ | ៣៩០ |
| | គ.២ | ៣៧០ |
| | គ.៣ | ៣៥២ |
| គ.១.១ | គ.៤ | ៣៣៥ |
| គ.១.២ | គ.៥ | ៣២១ |
| គ.១.៣ | គ.៦ | ៣០៧ |
| គ.១.៤ | គ.៧ | ២៩៥ |
| គ.២.១ | | |
| គ.១.៥ | គ.៨ | ២៨៤ |
| គ.១.៦ | | |
| គ.២.២ | | |
| គ.២.៣ | | |
| គ.២.៤ | | |
| គ.២.៥ | គ.៩ | ២៧៤ |
| គ.២.៦ | | |
| គ.២.៧ | | |
| គ.២.៨ | | |
| គ.២.៩ | | |
| គ.២.១០ | | |
| គ.៣.១ | | |
| គ.៣.២ | | |
| គ.៣.៣ | | |
| គ.៣.៤ | | |
| គ.៣.៥ | | |
| គ.៣.៦ | | |
| គ.៣.៧ | | |
| គ.៣.៨ | | |
| គ.៣.៩ | | |
| គ.៣.១០ | | |
| គ.៣.១១ | | |
| គ.៣.១២ | | |
| គ.៣.១៣ | | |
| គ.៣.១៤ | | |
| | គ.១០ | ២៦៥ |

**មាត្រា ២៣**:

មន្ត្រីរាជការស៊ីវិលនៃប្រភេទក្របខណ្ឌ ឃ បច្ចុប្បន្ន ចាប់ពី ឃ.១៤ ដល់ ឃ.១ ដែលសន្ទស្សន៍បៀវត្សក្រោយពីការកែសម្រួលបន្ថែមបៀវត្សមូលដ្ឋាន ៨០.០០០(ប៉ែតសិបពាន់)រៀលក្នុងមួយខែ មានចំនួនស្មើនឹង ២៦៣(ពីររយហុកសិបបី) ត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌ គ ថ្មី ថ្នាក់លេខ១០(ដប់) (គ.១០) ដែលមានសន្ទស្សន៍ស្មើនឹង ២៦៥(ពីររយហុកសិបប្រាំ)។

**មាត្រា ២៤**:

ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំការធ្វើសមាហរណកម្មខាងលើនេះ តាមប្រព័ន្ធព័ត៌មានវិទ្យា។

ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មីរបស់មន្ត្រីរាជការស៊ីវិល ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

# ជំពូកទី ៧
# អន្តរប្បញ្ញត្តិ

**មាត្រា ២៥:**

លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិល ត្រូវធ្វើការរៀបចំបញ្ចូលទៅតាមក្របខណ្ឌនិងអង្គនីមួយៗ ព្រមទាំងត្រូវរៀបចំកែសម្រួលឱ្យស្របតាមបទបញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា ២៦:**

លិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងមន្ត្រីរាជការស៊ីវិលជាធរមាន ត្រូវមានសុពលភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីដែលត្រូវរៀបចំឡើង ដើម្បីកែសម្រួលការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលឱ្យស្របតាមបទបញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

# ជំពូកទី ៨
# អវសានបញ្ញត្តិ

**មាត្រា ២៧:**

ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ត្រូវជំនួសដោយព្រះរាជក្រឹត្យនេះ និង បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ២៨:**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៤

[illegible]

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហត្ថលេខា**

**ពេជ្រ ប៊ុនធិន**

លេខ:១២០៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**